ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ១០៥៤ សណ៣

# សេចក្តីជូនដំណឹង

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សិស្ស-និស្សិត ដែលមានបំណងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ឲ្យបានជ្រាបថា ក្រសួងមហាផ្ទៃ សម្រេចបើកឲ្យមានការប្រឡងជ្រើសរើសសិស្ស-និស្សិតបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៤ ដើម្បីទៅបម្រើការងារនៅតាមរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងនៅតាមបណ្ណាពន្ធនាគាររាជធានី ពន្ធនាគារខេត្ត ដូចខាងក្រោម ៖

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌជ្រើសរើសសម្រាប់ឆ្នាំ ២០១៤ | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រីក្រមការ | លេខាធិការរដ្ឋបាល | អនុរក្សពន្ធនាគារ | សរុប | |
| ១ | ទីស្តីការក្រសួង | ៨ | ១១ | ១៥ | | ៣៤ | |
| ២ | ខេត្តតាកែវ | ៣ | ៤ | ១៥ | | ២២ | |
| ៣ | ខេត្តកណ្តាល | ៣ | ៤ | ៩ | | ១៦ | |
| ៤ | រាជធានីភ្នំពេញ | ៣ | ៤ | ១០ | ៦ (ស្រី ៣) | ២៣ | |
| ៥ | ខេត្តស្វាយរៀង | ៣ | ៣ | ៤ | | ១០ | |
| ៦ | ខេត្តព្រៃវែង | ៣ | ៣ | ១០ | ៦ (ស្រី ២) | ២២ | |
| ៧ | ខេត្តកំពង់ចាម | ៣ | ៤ | ១៥ | | ២២ | |
| ៨ | ខេត្តកំពង់ធំ | ៣ | ៣ | ១៤ | | ២០ | |
| ៩ | ខេត្តសៀមរាប | ៣ | ៤ | ១០ | | ១៧ | |
| ១០ | ខេត្តព្រះវិហារ | ៣ | ៤ | ៥ | ៧ (ស្រី ១) | ១៩ | |
| ១១ | ខេត្តបាត់ដំបង | ៣ | ៤ | ១៥ | | ២២ | |
| ១២ | ខេត្តកំពង់ឆ្នាំង | ៣ | ៤ | ១១ | | ១៨ | |
| ១៣ | ខេត្តប៉ៃលិន | ២ | ២ | ៣ | ៥ (ស្រី ១) | ១២ | |
| ១៤ | ខេត្តពោធិ៍សាត់ | ៣ | ៤ | ១០ | ៧ (ស្រី ១) | ២៤ | |
| ១៥ | ខេត្តកោះកុង | ៣ | ៤ | ៦ | ៧ (ស្រី ១) | ២០ | |
| ១៦ | ខេត្តព្រះសីហនុ | ៣ | ៤ | ៨ | | ១៥ | |
| ១៧ | ខេត្តកំពត | ៣ | ៤ | ១០ | | ១៧ | |
| ១៨ | ខេត្តកំពង់ស្ពឺ | ៣ | ៤ | ១០ | ៧ (ស្រី ០) | ២៤ | |
| ១៩ | ខេត្តកែប | ២ | ២ | ៤ | | ៨ | |
| ២០ | ខេត្តក្រចេះ | ៣ | ៤ | ៣ | ៦ (ស្រី ១) | ១៦ | |
| ២១ | ខេត្តស្ទឹងត្រែង | ៣ | ៤ | ៧ | ៧ (ស្រី ១) | ២១ | |
| ២២ | ខេត្តរតនគិរី | ៣ | ៤ | ៨ | ៧ (ស្រី ០) | ២២ | |
| ២៣ | ខេត្តមណ្ឌលគិរី | ៣ | ៤ | ៥ | ៩ (ស្រី ២) | ២១ | |
| ២៤ | ខេត្តបន្ទាយមានជ័យ | ៣ | ៤ | ៨ | | ១៥ | |
| ២៥ | ខេត្តឧត្តរមានជ័យ | ៣ | ៤ | ៥ | ៦ (ស្រី ២) | ១៨ | |
| | សរុប | ៧៨ | ១០០ | ២២០ | ៨០ (ស្រី ១៥) | ៤៧៨ | |

- មណ្ឌលប្រឡងត្រូវបានកំណត់ :

ក/- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ កំណត់ឲ្យមាន ៧ មណ្ឌលប្រឡង :

**១- មណ្ឌលប្រឡងរាជធានីភ្នំពេញ :** សម្រាប់បេក្ខជនមកពី ទីស្តីការក្រសួង រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តតាកែវ ។

**២- មណ្ឌលប្រឡងខេត្តកំពង់ចាម :** សម្រាប់បេក្ខជនមកពី ខេត្តកំពង់ចាម ខេត្តស្វាយរៀង និងខេត្តព្រៃវែង ។

**៣- មណ្ឌលប្រឡងខេត្តកំពង់ធំ :** សម្រាប់បេក្ខជនមកពី ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តព្រះវិហារ ។

**៤- មណ្ឌលប្រឡងខេត្តបាត់ដំបង :** សម្រាប់បេក្ខជនមកពី ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ។

**៥- មណ្ឌលប្រឡងខេត្តព្រះសីហនុ :** សម្រាប់បេក្ខជនមកពី ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកោះកុង ។

**៦- មណ្ឌលប្រឡងខេត្តក្រចេះ :** សម្រាប់បេក្ខជនមកពី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តមណ្ឌលគីរី ។

**៧- មណ្ឌលប្រឡងខេត្តបន្ទាយមានជ័យ :** សម្រាប់បេក្ខជនមកពី ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ។

ខ/- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងក្របខ័ណ្ឌអនុរក្ស កំណត់ឲ្យមាន ២៤ មណ្ឌលប្រឡង ស្ថិតនៅតាមសាលារាជធានី និងសាលាខេត្ត ដែលបេក្ខជនបានដាក់ពាក្យសុំបម្រើការងារ ។

- បេក្ខជនដែលមានបំណងចូលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ត្រូវទៅដាក់ពាក្យសុំចុះឈ្មោះដើម្បីចូលរួមប្រឡងប្រជែងនៅ ការិយាល័យក្របខ័ណ្ឌ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។

- បេក្ខជនដែលមានបំណងចូលបម្រើការងារនៅតាមរចនាសម្ព័ន្ធចំណុះឲ្យសាលារាជធានី-ខេត្ត និងតាមពន្ធនាគាររាជធានី-ខេត្ត ត្រូវទៅដាក់ពាក្យសុំនៅតាមសាលារាជធានី និងសាលាខេត្តសាមី នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ **ម៉ោង ១៧ : ០០ នាទី នាថ្ងៃសុក្រ ទី៣០ ខែឧសភា ឆ្នាំ២០១៤** ជាកាលបរិច្ឆេទកំណត់ចុងក្រោយ ។

កាលបរិច្ឆេទប្រឡងនៅថ្ងៃ **អាទិត្យ ទី២៩ ខែមិថុនា ឆ្នាំ ២០១៤** ។

ព័ត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅតាមការិយាល័យទទួលពាក្យសុំចុះឈ្មោះប្រឡងនៅតាមទីកន្លែងដែលបានកំណត់ នៅរៀងរាល់ម៉ោងធ្វើការ ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងមុខងារសាធារណៈ

(ដើម្បីជូនជ្រាប)

- សាលារាជធានី និងគ្រប់សាលាខេត្ត

(ដើម្បីផ្សព្វផ្សាយ និងអនុវត្តន៍)

- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៥៣៥ ប្រក

# ប្រកាស
## ស្តីពី
## ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុង ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ ២០១៤

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញ អនុក្រឹត្យលេខ ១៦ អនក្រ.ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ២២៣១ មស.ក្រឧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ .-**

បើកឲ្យមានការប្រឡងប្រជែងជ្រើសរើសបេក្ខជនជា សិស្ស-និស្សិត ឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៤ ចំនួន ៤៧៨ នាក់ ដើម្បីឲ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងពន្ធនាគាររាជធានី ខេត្ត ដូចខាងក្រោម ៖

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ចំនួន ៧៨ នាក់
- ក្របខ័ណ្ឌមន្ត្រីក្រមការ ចំនួន ១០០ នាក់
- ក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាល ចំនួន ២២០ នាក់
- ក្របខ័ណ្ឌមន្ត្រីអនុរក្សពន្ធនាគារ ចំនួន ៨០ នាក់

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ សម្រាប់ឆ្នាំ ២០១៤ | | | | ចំនួនសរុប |
|---|---|---|---|---|---|---|
| | | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រីក្រមការ | លេខាធិការរដ្ឋបាល | អនុរក្សពន្ធនាគារ | |
| | ក. រដ្ឋបាលថ្នាក់ជាតិ | | | | | |
| ១ | ទីស្តីការក្រសួង | ៨ | ១១ | ១៥ | | ៣៤ |

| | | | | | | |
|---|---|---|---|---|---|---|
| | **ខ. រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | |
| **១** | **ខេត្តតាកែវ** | ៣ | ៤ | ១៥ | | **២២** |
| ១/១ | សាលាខេត្ត | ១ | ២ | ២ | | |
| ១/២ | ស្រុកកោះអណ្ដែត | ១ | ១ | ២ | | |
| ១/៣ | ស្រុកគីរីវង្ស | ១ | ១ | ២ | | |
| ១/៤ | ស្រុកត្រាំកក់ | | | ២ | | |
| ១/៥ | ក្រុងដូនកែវ | | | ២ | | |
| ១/៦ | ស្រុកបាទី | | | ២ | | |
| ១/៧ | ស្រុកសំរោង | | | ៣ | | |
| **២** | **ខេត្តកណ្ដាល** | ៣ | ៤ | ៩ | | **១៦** |
| ២/១ | សាលាៈខេត្ត | ២ | ១ | ២ | | |
| ២/២/ | ក្រុងតាខ្មៅ | ១ | ១ | ១ | | |
| ២/៣ | ស្រុកពញាឮ | | | ២ | | |
| ២/៤ | ស្រុកកោះធំ | | ១ | | | |
| ២/៥ | ស្រុកលើកដែក | | | ២ | | |
| ២/៦ | ស្រុកស្អាង | | ១ | | | |
| ២/៧ | ស្រុកអង្គស្នួល | | | ២ | | |
| **៣** | **រាជធានីភ្នំពេញ** | ៣ | ៤ | ១០ | ៦ (ស្រី ៣) | **២៣** |
| ៣/១ | សាលារាជធានី | ១ | ២ | ១ | | |
| ៣/២ | ខណ្ឌពោធិ៍សែនជ័យ | | ១ | ២ | | |
| ៣/៣ | ខណ្ឌចំការមន | ១ | | ២ | | |
| ៣/៤ | ខណ្ឌទួលគោក | | ១ | ២ | | |
| ៣/៥ | ខណ្ឌសែនសុខ | | | ២ | | |
| ៣/៦ | ខណ្ឌដូនពេញ | ១ | | ១ | | |
| **៤** | **ខេត្តស្វាយរៀង** | ៣ | ៣ | ៤ | | **១០** |
| ៤/១ | សាលាខេត្ត | ២ | ១ | ២ | | |
| ៤/២ | ក្រុងបាវិត | ១ | ១ | | | |
| ៤/៣ | ស្រុកស្វាយទៀប | | ១ | ២ | | |
| **៥** | **ខេត្តព្រៃវែង** | ៣ | ៣ | ១០ | ៦ (ស្រី ២) | **២២** |
| ៥/១ | សាលាខេត្ត | ២ | ១ | ២ | | |
| ៥/២ | ស្រុកពោធិ៍រៀង | | ១ | ២ | | |
| ៥/៣ | ក្រុងព្រៃវែង | ១ | | ២ | | |
| ៥/៤ | ស្រុកស៊ីធរកណ្ដាល | | ១ | ២ | | |
| ៥/៥ | ស្រុកកំពង់ត្របែក | | | ២ | | |
| **៦** | **ខេត្តសៀមរាប** | ៣ | ៤ | ១០ | | **១៧** |
| ៦/១ | សាលាខេត្ត | ២ | | ២ | | |
| ៦/២ | ក្រុងសៀមរាប | | ២ | ២ | | |
| ៦/៣ | ស្រុកសូត្រនិគម | | ១ | ២ | | |
| ៦/៤ | ស្រុកក្រឡាញ់ | | ១ | ១ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦/៥ | ស្រុកបន្ទាយស្រី | ១ | | ១ | | |
| ៦/៦ | ស្រុកអង្គរធំ | | | ២ | | |
| **៧** | **ខេត្តប៉ៃលិន** | ២ | ២ | ៣ | ៥ (ស្រី ១) | **១២** |
| ៧/១ | សាលាខេត្ត | ១ | | ១ | | |
| ៧/២ | ក្រុងប៉ៃលិន | | ១ | ១ | | |
| ៧/៣ | ស្រុកសាលាក្រៅ | ១ | ១ | ១ | | |
| **៨** | **ខេត្តកំពត** | ៣ | ៤ | ១០ | | **១៧** |
| ៨/១ | សាលាខេត្ត | ២ | ១ | ២ | | |
| ៨/២ | ស្រុកទឹកឈូរ | | ១ | ២ | | |
| ៨/៣ | ស្រុកឈូក | ១ | ១ | ២ | | |
| ៨/៤ | ស្រុកកំពង់ត្រាច | | ១ | ២ | | |
| ៨/៥ | ស្រុកដងទង់ | | | ២ | | |
| **៩** | **ខេត្តបាត់ដំបង** | ៣ | ៤ | ១៥ | | **២២** |
| ៩/១ | សាលាខេត្ត | ១ | ១ | ៤ | | |
| ៩/២ | ក្រុងបាត់ដំបង | | ១ | ២ | | |
| ៩/៣ | ស្រុកបវេល | ១ | | ៣ | | |
| ៩/៤ | ស្រុកថ្មគោល | ១ | | ២ | | |
| ១០/៥ | ស្រុកបាណន់ | | ២ | ២ | | |
| ១០/៦ | ស្រុកមោងឫស្សី | | | ២ | | |
| **១០** | **ខេត្តក្រចេះ** | ៣ | ៤ | ៣ | ៦ (ស្រី ១) | **១៦** |
| ១០/១ | សាលាខេត្ត | ១ | ១ | ២ | | |
| ១០/២ | ស្រុកឆ្លូង | | ១ | ១ | | |
| ១០/៣ | ស្រុកស្នួល | ១ | ១ | | | |
| ១០/៤ | ស្រុកសំបូរ | ១ | ១ | | | |
| **១១** | **ខេត្តពោធិ៍សាត់** | ៣ | ៤ | ១០ | ៧ (ស្រី ១) | **២៤** |
| ១១/១ | សាលាខេត្ត | ១ | ២ | ៣ | | |
| ១១/២ | ស្រុកសំពៅមាស | | ២ | ២ | | |
| ១១/៣ | ស្រុកក្រគរ | ១ | | ២ | | |
| ១១/៤ | ស្រុកបាកាន | ១ | | ៣ | | |
| **១២** | **ខេត្តកំពង់ចាម** | ៣ | ៤ | ១៥ | | **២២** |
| ១២/១ | សាលាខេត្ត | ២ | ២ | | | |
| ១២/២ | ក្រុងកំពង់ចាម | | | ២ | | |
| ១២/៣ | ស្រុកចំការលើ | | | ២ | | |
| ១២/៤ | ស្រុកព្រៃឈរ | | | ២ | | |
| ១២/៥ | ស្រុកជើងព្រៃ | | ១ | ២ | | |
| ១២/៦ | ស្រុកបាធាយ | ១ | | ១ | | |
| ១២/៧ | ស្រុកត្បូងឃ្មុំ | | ១ | ២ | | |
| ១២/៨ | ស្រុកពញាក្រែក | | | ២ | | |
| ១២/៩ | ស្រុកកោះសូទិន | | | ២ | | |

| | | | | | | |
|---|---|---|---|---|---|---|
| **១៣** | **ខេត្តកំពង់ឆ្នាំង** | ៣ | ៤ | ១១ | | ១៨ |
| ១៣/១ | សាលាខេត្ត | ២ | | ១ | | |
| ១៣/២ | ស្រុកកំពង់លែង | | ១ | ២ | | |
| ១៣/៣ | ស្រុកជលគីរី | | ១ | ២ | | |
| ១៣/៤ | ស្រុករលាប្អៀរ | ១ | ១ | ២ | | |
| ១៣/៥ | ស្រុកទឹកផុស | | ១ | ២ | | |
| ១៣/៦ | ស្រុកសាមគ្គីមានជ័យ | | | ២ | | |
| **១៤** | **ខេត្តរតនគីរី** | ៣ | ៤ | ៨ | ៧ (ស្រី 0) | ២២ |
| ១៤/១ | សាលាខេត្ត | ២ | | ២ | | |
| ១៤/២ | ក្រុងបាលុង | ១ | ១ | ១ | | |
| ១៤/៣ | ស្រុកលំផាត់ | | ១ | ១ | | |
| ១៤/៤ | ស្រុកវើនសៃ | | ១ | ២ | | |
| ១៤/៥ | ស្រុកអូរជុំ | | ១ | ២ | | |
| **១៥** | **ខេត្តកោះកុង** | ៣ | ៤ | ៦ | ៧ (ស្រី ១) | ២០ |
| ១៥/១ | សាលាខេត្ត | ២ | | ២ | | |
| ១៥/២ | ក្រុងខេមរភូមិន្ទ | | ១ | ១ | | |
| ១៥/៣ | ស្រុកបូទុមសាគរ | ១ | ១ | ១ | | |
| ១៥/៤ | ស្រុកស្រែអំបិល | | ១ | ១ | | |
| ១៥/៥ | ស្រុកគីរីសាគរ | | ១ | ១ | | |
| **១៦** | **ខេត្តកែប** | ២ | ២ | ៤ | | ៨ |
| ១៦/១ | សាលាខេត្ត | | ២ | ២ | | |
| ១៦/២ | ក្រុងកែប | ១ | | ១ | | |
| ១៦/៣ | ស្រុកដំណាក់ចង្អើរ | ១ | | ១ | | |
| **១៧** | **ខេត្តបន្ទាយមានជ័យ** | ៣ | ៤ | ៨ | | ១៥ |
| ១៧/១ | សាលាខេត្ត | ២ | ១ | ២ | | |
| ១៧/២ | ក្រុងសិរីសោភ័ណ | | ១ | ២ | | |
| ១៧/៣ | ស្រុកភ្នំស្រុក | ១ | ១ | ២ | | |
| ១៧/៤ | ស្រុកអូរជ្រៅ | | ១ | ២ | | |
| **១៨** | **ខេត្តកំពង់ធំ** | ៣ | ៣ | ១៤ | | ២០ |
| ១៨/១ | សាលាខេត្ត | ១ | ១ | ២ | | |
| ១៨/២ | ក្រុងស្ទឹងសែន | | | ២ | | |
| ១៨/៣ | ស្រុកស្ទោង | ១ | | ២ | | |
| ១៨/៤ | ស្រុកកំពង់ស្វាយ | | ២ | ២ | | |
| ១៨/៥ | ស្រុកសន្ទុក | ១ | | ២ | | |
| ១៨/៦ | ស្រុកបារាយណ៍ | | | ២ | | |
| ១៨/៧ | ស្រុកប្រាសាទសំបូរ | | | ២ | | |
| **១៩** | **ខេត្តកំពង់ស្ពឺ** | ៣ | ៤ | ១០ | ៧ (ស្រី 0) | ២៤ |
| ១៩/១ | សាលាខេត្ត | ២ | ២ | ២ | | |
| ១៩/២ | ស្រុកថ្ពង | | ២ | ២ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៩/៣ | ស្រុកគងពិសី | | | ២ | | |
| ១៩/៤ | ស្រុកបសេដ្ឋ | ១ | | ២ | | |
| ១៩/៥ | ស្រុកភ្នំស្រួច | | | ២ | | |
| **២០** | **ខេត្តព្រះសីហនុ** | ៣ | ៤ | ៨ | | ១៥ |
| ២០/១ | សាលាខេត្ត | ២ | | ២ | | |
| ២០/២ | ស្រុកព្រៃនប់ | | ១ | ២ | | |
| ២០/៣ | ស្រុកកំពង់សីលា | ១ | ១ | ២ | | |
| ២០/៤ | ស្រុកស្ទឹងហាវ | | ២ | ២ | | |
| **២១** | **ខេត្តមណ្ឌលគិរី** | ៣ | ៤ | ៥ | ៩ (ស្រី ២) | ២១ |
| ២១/១ | សាលាខេត្ត | ២ | ២ | ២ | | |
| ២១/២ | ស្រុកកោះញែក | | ១ | | | |
| ២១/៣ | ស្រុកកែវសីមា | ១ | | ១ | | |
| ២១/៤ | ស្រុកពេជ្រាដា | | | ២ | | |
| ២១/៥ | ស្រុកអូររាំង | | ១ | | | |
| **២២** | **ខេត្តព្រះវិហារ** | ៣ | ៤ | ៥ | ៧ (ស្រី ១) | ១៩ |
| ២២/១ | សាលាខេត្ត | ២ | | ២ | | |
| ២២/២ | ស្រុកសង្គមថ្មី | | ២ | | | |
| ២២/៣ | ស្រុកជាំក្សាន្ត | ១ | ១ | | | |
| ២២/៤ | ស្រុកឆែប | | | ២ | | |
| ២២/៥ | ស្រុកត្បែងមានជ័យ | | ១ | ១ | | |
| **២៣** | **ខេត្តស្ទឹងត្រែង** | ៣ | ៤ | ៧ | ៧ (ស្រី ១) | ២១ |
| ២៣/១ | សាលាខេត្ត | ២ | | ២ | | |
| ២៣/២ | ស្រុកសៀមប៉ាង | | ២ | ២ | | |
| ២៣/៣ | ស្រុកសេសាន | ១ | ១ | ១ | | |
| ២៣/៤ | ស្រុកសៀមបូក | | ១ | ២ | | |
| **២៤** | **ខេត្តឧត្តរមានជ័យ** | ៣ | ៤ | ៥ | ៦ (ស្រី ២) | ១៨ |
| ២៤/១ | សាលាខេត្ត | ២ | ១ | ២ | | |
| ២៤/២ | ស្រុកចុងកាល | | ១ | ១ | | |
| ២៤/៣ | ស្រុកអន្លង់វែង | ១ | ១ | ១ | | |
| ២៤/៤ | ស្រុកបន្ទាយអំពិល | | ១ | ១ | | |
| | **សរុប** | ៧៨ | ១០០ | ២២០ | ៨០ (ស្រី ១៥) | ៤៧៨ |

## ប្រការ ២ .–

បេក្ខជនទាំងពីរភេទមានសិទ្ធិអាចសុំចុះឈ្មោះប្រឡងប្រជែងបានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**ក-លក្ខខណ្ឌនៃការជ្រើសរើស ៖**

១- មានសញ្ជាតិខ្មែរ

២- មានកាយសម្បទាគ្រប់លក្ខណៈ មានសុខភាពល្អ និងជនពិការដែលមានសមត្ថភាពសមស្រប

៣- មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ។

៤- បេក្ខជនត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣០ឆ្នាំ យ៉ាងច្រើនបំផុត ចំពោះបេក្ខជនដែលមានសញ្ញាបត្រឧត្តមសិក្សា។

៥- បេក្ខនារី ជនពិការដែលមានសមត្ថភាព និងបេក្ខជនដែលនៅតំបន់ដាច់ស្រយាលត្រូវបានផ្តល់ការលើកទឹកចិត្តនៅក្នុងការជ្រើសរើសនេះ។

៦- បេក្ខជនជាសិស្សត្រូវមានសញ្ញាប័ត្រ៖

- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖** បេក្ខជនទាំងពីរភេទជា សិស្ស-និស្សិត ត្រូវមានសញ្ញាបត្រ បរិញ្ញាបត្រនីតិសាស្ត្រ បរិញ្ញាបត្រសេដ្ឋកិច្ច បរិញ្ញាបត្រស្ថាបត្យកម្ម បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាប័ត្របរិញ្ញាប័ត្រដែលមានតម្លៃស្មើ ។
- **ក្របខ័ណ្ឌមន្ត្រីក្រមការ ៖** បេក្ខជនទាំងពីរភេទជា សិស្ស-និស្សិត ត្រូវមានសញ្ញាប័ត្រយ៉ាងទាបមធ្យមសិក្សានីតិសាស្ត្រ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ ។
- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖** បេក្ខជនទាំងពីរភេទជាសិស្ស និស្សិតត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងសញ្ញាប័ត្រមធ្យមទុតិយភូមិ ។
- **ក្របខ័ណ្ឌមន្ត្រីអនុរក្សពន្ធនាគារ ៖** បេក្ខជនទាំងពីរភេទជា សិស្ស-និស្សិត ត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងសញ្ញាប័ត្រមធ្យមទុតិយភូមិ ដោយឡែកសម្រាប់ពន្ធនាគារខេត្តព្រះវិហារបេក្ខជនទាំងពីរភេទជា សិស្ស-និស្សិត ត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងសញ្ញាប័ត្រមធ្យមទុតិយភូមិឬត្រឹមថ្នាក់ទី១២ បេក្ខជនទាំងពីរភេទត្រូវមានកំពស់ចាប់ពី **១.៦៥ ម ឡើងសម្រាប់បុរស និងមានកំពស់ចាប់ពី ១.៥៥ ម ឡើងសម្រាប់បេក្ខជនជាស្ត្រី** ។

ក្នុងករណីចាំបាច់គណៈកម្មការកណ្តាលរៀបចំការប្រឡង អាចកំណត់សញ្ញាបត្រជំនាញសម្រាប់បេក្ខជនជាសិស្ស-និស្សិត ដែលត្រូវប្រឡងចូលក្របខ័ណ្ឌទៅតាមតម្រូវការសម្រាប់អង្គភាពនីមួយៗ នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ខ-សំណុំលិខិតដែលត្រូវចំពេញមាន ៖**

១- ពាក្យសុំចុះឈ្មោះប្រឡង មានបិទតែមប្រៃយ៍........ ចំនួន ០១ ច្បាប់
២- សេចក្តីចម្លងសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សា ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ.. ចំនួន ០១ ច្បាប់
៣- ជីវប្រវត្តិមានបិទរូបថត ៤x៦ ........ ចំនួន ០១ ច្បាប់
៤- រូបថត ៤x៦........ ចំនួន០៣ សន្លឹក
៥- បង្កាន់ដៃទទួលពាក្យប្រឡង ........ ចំនួន ០១ ច្បាប់
៦- សលាកប័ត្រឯកត្តជន........ ចំនួន ០១ ច្បាប់
៧- លិខិតបញ្ជាក់កិរិយាមាយាទរបស់សាមីខ្លួន ចេញដោយអាជ្ញាធរមូលដ្ឋាន........ ចំនួន ០១ ច្បាប់
៨- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត........ ចំនួន ០១ ច្បាប់
៩- សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ........ ចំនួន ០១ ច្បាប់

## ប្រការ ៣ .-

វិញ្ញាសា និងថេរវេលា នៃការប្រឡងជ្រើសរើស ៖

- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ៖**
  - ១. ជំនាញឯកទេស........ រយៈពេល ០១ម៉ោង ៣០ នាទី
  - ២. ភាសាអង់គ្លេស........ រយៈពេល ០១ម៉ោង ៣០ នាទី
- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងក្របខ័ណ្ឌអនុរក្សពន្ធនាគារ ៖**
  - ១. ចំណេះដឹងទូទៅ និងគណិតវិទ្យា ........ រយៈពេល ០១ម៉ោង ៣០ នាទី
  - ២.តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល ........ រយៈពេល ០១ ម៉ោង ៣០នាទី

## ប្រការ ៤ .-

ទីកន្លែងទទួលពាក្យត្រូវបានកំណត់ នៅនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលារាជធានីភ្នំពេញ គ្រប់សាលាខេត្ត និងនៅតាមពន្ធនាគាររាជធានី-ខេត្ត ដែលបានកំណត់ឲ្យមានការជ្រើសរើស បេក្ខជន ត្រូវយកពាក្យសុំចុះឈ្មោះ ប្រឡងទៅដាក់នៅតាមទីកន្លែងដែលសាមីខ្លួន បានស្ម័គ្រចិត្តទៅបម្រើការងារ ។

**មណ្ឌលប្រឡង កាលបរិច្ឆេទទទួលពាក្យប្រឡង និងកាលបរិច្ឆេទប្រឡង :**

- មណ្ឌលប្រឡងត្រូវបានកំណត់ :

ក/- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ កំណត់ឲ្យមាន ៧ មណ្ឌលប្រឡង :

**១- មណ្ឌលប្រឡងរាជធានីភ្នំពេញ :** សម្រាប់បេក្ខជនមកពី ទីស្តីការក្រសួង រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តតាកែវ ។

៤- មណ្ឌលប្រឡងខេត្តបាត់ដំបង : សម្រាប់បេក្ខជនមកព ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ។

៥- មណ្ឌលប្រឡងខេត្តព្រះសីហនុ : សម្រាប់បេក្ខជនមកពី ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកោះកុង ។

៦- មណ្ឌលប្រឡងខេត្តក្រចេះ : សម្រាប់បេក្ខជនមកពី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និង ខេត្តមណ្ឌលគីរី ។

៧- មណ្ឌលប្រឡងខេត្តបន្ទាយមានជ័យ : សម្រាប់បេក្ខជនមកពី ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ។

ខ/- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងក្របខ័ណ្ឌអនុរក្ស កំណត់ឲ្យមាន ២៤ មណ្ឌលប្រឡង ស្ថិតនៅតាមសាលារាជធានី និងសាលាខេត្ត ដែលបេក្ខជនបានដាក់ពាក្យសុំបម្រើការងារ ។

- កាលបរិច្ឆេទទទួលពាក្យប្រឡងចាប់ពីថ្ងៃជូនដំណឹង រហូតដល់ថ្ងៃ សុក្រ **ទី៣០ ខែឧសភា ឆ្នាំ២០១៤** ។
- កាលបរិច្ឆេទប្រឡងនៅថ្ងៃ **អាទិត្យ ទី២៩ ខែមិថុនា ឆ្នាំ ២០១៤** ។

## ប្រការ ៥ .—

ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ត្រូវដឹកនាំដោយគណៈកម្មការកណ្តាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងរាជធានី-ខេត្ត ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ គណៈកម្មការកណ្តាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងរាជធានី-ខេត្ត មានសិទ្ធរៀងៗខ្លួន ក្នុងការប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ និងត្រារដ្ឋបាលរាជធានី រដ្ឋបាលខេត្ត ។

## ប្រការ ៦ .—

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ប្រធានក្រុមប្រឹក្សា និងគណៈអភិបាលគ្រប់ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

***កន្លែងទទួល:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*

*(ដើម្បីជូនជ្រាប)*

- *ដូចប្រការ៦ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*